# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# គម្រោងកែលម្អការតភ្ជាប់ផ្លូវថ្នល់នៅកម្ពុជាP169930
# និងហិរញ្ញប្បទានបន្ថែម P181396

## ពង្រៀង

# ផែនការស្តីពីការប្តេជ្ញាចិត្តផ្នែកបរិស្ថាន និងសង្គម

វិច្ឆិកា ២០២៣

# ផែនការស្តីពីការប្តេជ្ញាចិត្តផ្នែកបរិស្ថាន និងសង្គម

**១.** ព្រះរាជាណាចក្រកម្ពុជា (ភាគីទទួលកម្ចី) ដែលមានក្រសួងសាធារណការ និងដឹកជញ្ជូន (MPWT) និងក្រសួងអភិវឌ្ឍន៍ជនបទ (MRD) ជាអ្នកអនុវត្តគម្រោងកែលម្អការតភ្ជាប់ផ្លូវថ្នល់នៅកម្ពុជា ដោយមានការចូលរួមពីអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ដូចមានចែងក្នុងកិច្ចព្រមព្រៀងហិរញ្ញប្បទាន។ សមាគមអភិវឌ្ឍន៍អន្តរជាតិ (ធនាគារ) បានយល់ព្រមផ្តល់ហិរញ្ញប្បទានដើម (P169930) និងហិរញ្ញប្បទានបន្ថែម (P181396) សម្រាប់គម្រោងដូចដែលមានចែងក្នុងកិច្ចព្រមព្រៀង។ ផែនការស្តីពីការប្តេជ្ញាចិត្តផ្នែកបរិស្ថាន និងសង្គម (ESCP) ថ្មី នេះជំនួសឲ្យ ផែនការស្តីពីការប្តេជ្ញាចិត្តផ្នែកបរិស្ថាន និងសង្គម មុន (ESCP) សម្រាប់ អនុវត្តគម្រោងទាំងគម្រោងដើម និងគម្រោងហិរញ្ញប្បទានបន្ថែមដែលលើកឡើងខាងលើ។

**២.** ភាគីទទួលកម្ចីត្រូវធានាថាគម្រោងនេះអនុវត្តដោយអនុលោមតាមស្តង់ដារសង្គម និងបរិស្ថាន(ESSs) និងផែនការស្តីពីការប្តេជ្ញាចិត្តផ្នែកបរិស្ថាន និងសង្គម (ESCP) ក្នុងលក្ខណៈដែលធនាគារអាចទទួលយកបាន ។ ផែនការស្តីពីការប្តេជ្ញាចិត្តផ្នែកបរិស្ថាន និងសង្គម (ESCP) គឺជាផ្នែកមួយនៃកិច្ចព្រមព្រៀងហិរញ្ញប្បទាន។ ប្រសិនបើគ្មានការកំណត់ន័យផ្សេងនៃពាក្យ ESCP នេះទេ ពាក្យសរសេរអក្សរធំដែលប្រើក្នុងឯកសារនេះ មានអត្ថន័យដូចដែលបានកំណត់ក្នុងកិច្ចព្រមព្រៀង ។

**៣.** ក្រៅពីការលើកឡើងខាងលើ ផែនការស្តីពីការប្តេជ្ញាចិត្តផ្នែកបរិស្ថាន និងសង្គម (ESCP) បានកំណត់នូវវិធានការ និងសកម្មភាពសំខាន់ៗដែលភាគីទទួលកម្ចីត្រូវអនុវត្ត រួមទាំងពេលវេលានៃសកម្មភាព និងវិធានការ ស្ថាប័ន បុគ្គលិក ការបណ្តុះបណ្តាល ការត្រួតពិនិត្យ ការរៀបចំរបាយការណ៍ និងការគ្រប់គ្រងបណ្តឹងសារទុក្ខ។ ESCP បានកំណត់នូវឧបករណ៍សង្គម និងបរិស្ថាន (E&S instruments) ដែលត្រូវអនុម័ត និងអនុវត្តក្នុងគម្រោង ដែលការងារទាំងអស់នេះនឹងត្រូវធ្វើការពិគ្រោះយោបល់ និងផ្សព្វផ្សាយជាមុន ស្របតាម ស្តង់ដាសង្គម និងបរិស្ថាន (ESS) និងជាទម្រង់ និងខ្លឹមសារ ដែលធនាគារអាចទទួលយកបាន។ នៅពេលទទួលយកទៅអនុវត្តន៍ ឧបករណ៍សង្គម និងបរិស្ថាន (E&S instruments) អាចត្រូវបានកែសម្រួលដោយមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយធនាគារជាមុន។

**៤.** ដូចដែលបានព្រមព្រៀងរវាងធនាគារ និងភាគីទទួលកម្ចី ផែនការស្តីពីការប្តេជ្ញាចិត្តផ្នែកបរិស្ថាន និងសង្គម (ESCP) នេះនឹងត្រូវបានកែសម្រួលទៅតាមពេលវេលាប្រសិនបើចាំបាច់ ក្នុងអំឡុងពេលអនុវត្តគម្រោង ដើម្បីឆ្លុះបញ្ចាំងពីការសម្របខ្លួននៃការគ្រប់គ្រងគម្រោងនៅពេលមានការប្រែប្រួល និងកាលៈទេសៈដែលមិនបានមើលឃើញទុកជាមុន។ ក្នុងកាលៈទេសៈបែបនេះ ភាគីទទួលកម្ចី មានក្រសួងសាធារណការ និងដឹកជញ្ជូន (MPWT) និងក្រសួង

អភិវឌ្ឍន៍ជនបទ (MRD) និងធនាគារយល់ព្រមធ្វើបច្ចុប្បន្នភាព ESCP ដើម្បីឆ្លើយតបការផ្លាស់ប្តូរទាំងនេះតាមរយៈការផ្លាស់ប្តូរលិខិតដែលបានចុះហត្ថលេខារវាងធនាគារនិងភាគីទទួលកម្ចី។ ភាគីកម្ចីត្រូវបង្ហាញ ផែនការស្តីពីការប្តេជ្ញាចិត្តផ្នែកបរិស្ថាន និងសង្គម (ESCP) ដែលត្រូវបានធ្វើបច្ចុប្បន្នភាពឱ្យបានឆាប់រហ័ស។

| ឧបករណ៍វាស់វែង និងសកម្មភាព | | ពេលវេលា | អង្គភាពទទួលខុសត្រូវ/អាជ្ញាធរ |
|---|---|---|---|
| ការត្រួតពិនិត្យ និងការរៀបចំរាយការណ៍ | | | |
| ក | **ការរៀបចំរបាយការណ៍ឲ្យបានទៀងទាត់**<br>ជាផ្នែកមួយនៃការរៀបចំរបាយការណ៍គម្រោងជាប្រចាំរបស់ខ្លួន អង្គភាពអនុវត្តគម្រោង ត្រូវរៀបចំរបាយការណ៍ដាក់ជូនធនាគារនូវរបាយការណ៍ត្រួតពិនិត្យជាប្រចាំស្ដីពីការអនុវត្ត ផ្នែកបរិស្ថាន សង្គម សុខភាព និងសុវត្ថិភាព (ESHS) របស់គម្រោង ប៉ុន្តែមិនកំណត់ចំពោះការអនុវត្ត ESCP។ ឯកសារ E&S មាននៅក្នុង ឯកសារ ESCP រៀបរាប់ពីសកម្មភាពចូលរួមរបស់អ្នកពាក់ព័ន្ធ ដំណើរការនៃយន្តការបណ្ដឹងសារទុក្ខ។ | - របាយការណ៍ប្រចាំត្រីមាស តាមរយៈការអនុវត្តគម្រោង<br>- របាយការណ៍ប្រចាំឆ្នាំ តាមរយៈការអនុវត្តគម្រោង | ក្រុមការងារអនុវត្តគម្រោង<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងអភិវឌ្ឍន៍ជនបទ |

| ឧបករណ៍វាស់វែង និងសកម្មភាព | | ពេលវេលា | អង្គភាពទទួលខុសត្រូវ/អាជ្ញាធរ |
|---|---|---|---|
| ២ | **ឧប្បត្តិហេតុ និងគ្រោះថ្នាក់**<br><br>**ការរៀបចំ និងដំណើរការយន្តការរាយការណ៍ពីបញ្ហាគ្រោះថ្នាក់**<br>ជូនដំណឹងដល់ធនាគារភ្លាមៗអំពីឧបទ្ទវហេតុ ឬគ្រោះថ្នាក់ណាមួយដែលទាក់ទងនឹងគម្រោងដែលមាន ឬទំនងជាមានផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន សហគមន៍ដែលរងផលប៉ះពាល់ សាធារណជន ឬកម្មករ រួមទាំងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកនៅលើផ្លូវគម្រោង និងឧប្បត្តិហេតុផ្សេងទៀតដែលបានកើតឡើងនៅកន្លែងគម្រោងសាងសង់ ឬទាក់ទងនឹងគម្រោងដែលផ្តល់ហិរញ្ញប្បទានដល់ការងារសាងសង់។<br>ផ្តល់ព័ត៌មានលម្អិតឲ្យបានគ្រប់គ្រាន់ ទាក់ទងនឹងឧបទ្ទវហេតុឬគ្រោះថ្នាក់ដោយបង្ហាញពីវិធានការភ្លាមៗដែលបានធ្វើឡើង ឬដែលគ្រោងនឹងធ្វើឡើងដើម្បីដោះស្រាយ និងព័ត៌មានដែលផ្តល់ដោយអ្នកម៉ៅការ និងអង្គភាពត្រួតពិនិត្យណាមួយតាមការសមស្រប។ | - ក្នុងរយៈពេលបីខែបន្ទាប់ពីប្រសិទ្ធភាពនៃគម្រោង (មុនពេលចាប់ផ្តើមការងារសាងសង់)<br><br>- ជូនដំណឹងដល់ធនាគារថាក្នុងរយៈពេល ៤៨ ម៉ោងបន្ទាប់ពីដឹងពីឧប្បត្តិហេតុឬគ្រោះថ្នាក់។ របាយការណ៍នឹងត្រូវបានផ្តល់ជូនក្នុងរយៈពេល ៣ ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីឧប្បត្តិហេតុឬគ្រោះថ្នាក់។ | ក្រុមការងារអនុវត្តគម្រោង<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន<br><br>- ក្រសួងអភិវឌ្ឍន៍ជនបទ |

| | | | |
|---|---|---|---|
| គ | **របាយការណ៍ប្រចាំខែរបស់អ្នកម៉ៅការ**<br>- បញ្ជូនរបាយការណ៍ត្រួតពិនិត្យប្រចាំខែ បូកសរុបការអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងសង្គម (ES) ទៅ ក្រុមការងារអនុវត្តគម្រោង (PITs) នៃ ក្រសួងសាធារណការ និងដឹកជញ្ជូន (MPWT) និង ក្រសួងអភិវឌ្ឍន៍ជនបទ(MRD) ។<br>- បញ្ជូនរបាយការណ៍ប្រចាំខែ ទៅធនាគារ ដោយក្រសួងសាធារណការ និងដឹកជញ្ជូន (MPWT) និង ក្រសួងអភិវឌ្ឍន៍ជនបទ(MRD) តាមការស្នើសុំ។ | - ប្រចាំខែ (និងតាមការស្នើសុំរបស់ធនាគារ) | - អ្នកម៉ៅការ (តាមរយៈក្រសួងសាធារណការ និងដឹកជញ្ជូន (MPWT) និង ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) ទៅធនាគារតាមការស្នើសុំ) |

| ឧបករណ៍វាស់វែង និងសកម្មភាព | | ពេលវេលា | អង្គភាពទទួលខុសត្រូវ/អាជ្ញាធរ |
|---|---|---|---|
| ESS 9: ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម | | | |
| ១.១ | **រចនាសម្ព័ន្ធ**<br>រក្សាក្រុមការងារអនុវត្តគម្រោង (PITs) នៅ MPWT និង MRD សម្រាប់អនុវត្តន៍ការងារតាមផ្នែករៀងៗខ្លួន។ ក្រុមការងារអនុវត្តគម្រោង (PITs) ត្រូវរើសបុគ្គលិកដែលមានសមត្ថភាពមកពីនាយកដ្ឋានរៀងៗខ្លួន ដើម្បីធានានូវការគ្រប់គ្រងហានិភ័យបានត្រឹមត្រូវ E&S ដូចខាងក្រោម÷<br>- នៅ MPWT PIT÷ មានមន្ត្រីបរិស្ថានមួយរូប និងមន្ត្រីសង្គមមួយរូបមកពីការិយាល័យសង្គម និងបរិស្ថាន (SEO) នៃ MPWT និង<br>- នៅ MRD PIT÷ មានមន្ត្រីបរិស្ថានមួយរូប និងមន្ត្រីសង្គមបីរូបមកពី DRR និង SEO ។ | - រក្សាទុកឲ្យបានពេញមួយវដ្តការអនុវត្តគម្រោង | - ក្រសួងសាធារណការ និងដឹកជញ្ជូន (MPWT)<br>- ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) |

| ឧបករណ៍វាស់វែង និងសកម្មភាព | | ពេលវេលា | អង្គភាពទទួលខុសត្រូវ/អាជ្ញាធរ |
|---|---|---|---|
| ១.២ | **ការវាយតម្លៃបរិស្ថាន និងសង្គម**<br>រក្សា និងអនុវត្តឱ្យបាននូវលក្ខខណ្ឌ ដែលធនាគារអាចទទួលយកបានស្របតាមឯកសារ E&S ដូចខាងក្រោម÷<br>- **សម្រាប់សមាសភាគទី** ១ ផ្នែកផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMPs)<br>- **សម្រាប់សមាសភាគទី** ២ ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) និង ESMPs ជាក់លាក់សម្រាប់ផ្លូវជនបទ | - បានអនុវត្តពេញមួយវដ្តនៃគម្រោង | - ក្រសួងសាធារណការ និងដឹកជញ្ជូន (MPWT)<br>- ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) |

| ឧបករណ៍វាស់វែង និងសកម្មភាព | | ពេលវេលា | អង្គភាពទទួលខុសត្រូវ/អាជ្ញាធរ |
|---|---|---|---|
| ១.៣ | **ឧបករណ៍ និងឧបករណ៍គ្រប់គ្រង**<br>- **សមាសភាគ ១** អនុវត្ត តាម ESMPs<br>- **សមាសភាគ ២** អនុវត្ត តាម ESMPs ជាក់លាក់តាមតម្រូវការ ស្របតាម ESMF និងក្នុងលក្ខខ័ណ្ឌដែលធនាគារអាចទទួលយកបាន។ | - អនុវត្តពេញមួយវដ្តនៃគម្រោង<br>- សមាសធាតុ 2 ESMPs ត្រូវបានអនុវត្តពេញមួយវដ្ត ស្របតាមកាលវិភាគនៃការសាងសង់ ដែលបានកំណត់ ដោយគិតគូរពីលក្ខណៈជាក់លាក់តាមរដូវកាលនៃតំបន់គម្រោង (ដូចដែលបានបញ្ជាក់នៅក្នុង ESMPs នីមួយៗ)<br>- | - ក្រសួងសាធារណការ និងដឹកជញ្ជូន និង<br>- ក្រសួងអភិវឌ្ឍន៍ជនបទ |
| ១.៤ | **ការគ្រប់គ្រងអ្នកម៉ៅការ**<br>ត្រូវធ្វើឱ្យប្រាកដថាអ្នកម៉ៅការគោរពតាមឯកសារ និងផែនការ E&S ដែលពាក់ព័ន្ធ និងនីតិវិធីគ្រប់គ្រងការងារ (LMP) ដែលត្រូវបានដាក់បញ្ចូលទៅក្នុងលក្ខណៈបច្ចេកទេស ESHS នៃកិច្ចសន្យានីមួយៗ។ | - ពេញមួយវដ្តនៃការអនុវត្តកិច្ចសន្យានីមួយៗ | - ក្រុមការងារអនុវត្តគម្រោងនៃក្រសួងសាធារណការ និងដឹកជញ្ជូន និង ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រុមអ្នកម៉ៅការ |

| ឧបករណ៍វាស់វែង និងសកម្មភាព | | ពេលវេលា | អង្គភាពទទួលខុសត្រូវ/អាជ្ញាធរ |
|---|---|---|---|
| ១.៥ | **ការផ្តល់ហិរញ្ញប្បទានសម្រាប់ការឆ្លើយតបបន្ទាន់**<br>ក. រក្សាគោលការណ៍ណែនាំ CERC ដែលរួមបញ្ចូលនូវការពិព័ណ៌នាការវាយតម្លៃលើ ESHS និងការគ្រប់គ្រងដែលរួមបញ្ចូល ESMF, RPF, IPPF, SEP, LMP និង ESMP នៅការដ្ឋានជាក់លាក់ សម្រាប់សមាសភាគទី១ និងទី២ដើម្បីអនុវត្តការឆ្លើយតបបន្ទាន់ ដោយយោងទៅលើ ESSs ។<br>ខ. ដោយអនុលោមតាមគោលការណ៍ណែនាំ CERC ផែនការសកម្មភាពបន្ទាន់ និង ESSs អនុវត្តន៍វិធានការ និងសកម្មភាពផ្សេងៗ ក្រោមក្របខ័ណ្ឌ E&S សូមមើលចំណុច 1.2, 2.1, 4.3, 5.1, 5.2, 7.1, 10.1 នៃឯកសារ ESCP ។ | - អនុវត្តពេញមួយវដ្តនៃការអនុវត្តគម្រោង | ក្រុមការងារអនុវត្តគម្រោង នៃក្រសួងសាធារណការ និងដឹកជញ្ជូន និង ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមមាន GDR ផងដែរ។ |
| ESS ២: | **ពលកម្ម និងលក្ខខណ្ឌការងារ** | | |

| | ឧបករណ៍វាស់វែង និងសកម្មភាព | ពេលវេលា | អង្គភាពទទួលខុសត្រូវ/អាជ្ញាធរ |
|---|---|---|---|
| ២.១ | **និតិវិធីគ្រប់គ្រងការងារ**<br>ត្រូវអនុវត្តនិតិវិធីគ្រប់គ្រងការងារ (LMP) សម្រាប់គម្រោង រួមមានលក្ខខណ្ឌការងារ ការគ្រប់គ្រងទំនាក់ទំនងកម្មករ សុខភាព និងសុវត្ថិភាពការងារ (រួមទាំងសម្ភារៈសុវត្ថិភាពផ្ទាល់ខ្លួន និងការត្រៀមលក្ខណៈសង្គ្រោះបន្ទាន់ និងការឆ្លើយតប) ក្រមសីលធម៌ (រួមមានពាក់ព័ន្ធ នឹង SEA និង SH) ពលកម្មដោយបង្ខំ ពលកម្មកុមារ ការរៀបចំបណ្តឹងសារទុក្ខសម្រាប់បុគ្គលិកគម្រោង និងតម្រូវការដែលអាចអនុវត្តបានសម្រាប់អ្នកម៉ៅការ អ្នកម៉ៅការបន្ត និងក្រុមហ៊ុនប្រឹក្សាបច្ចេកទេស។ | - អនុវត្តពេញមួយវដ្តនៃការអនុវត្តគម្រោង | - ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងអភិវឌ្ឍន៍ជនបទ និង<br>- ក្រុមអ្នកម៉ៅការ |
| ២.២ | **យន្តការបណ្តឹងសារទុក្ខសម្រាប់កម្មករគម្រោង**<br>រក្សា និងដំណើរការយន្តការបណ្តឹងសារទុក្ខសម្រាប់កម្មករគម្រោង ដូចដែលបានពិពណ៌នានៅក្នុង LMP និងស្របតាម ESS2។ | - អនុវត្តពេញមួយវដ្តនៃការអនុវត្តគម្រោង | - ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងអភិវឌ្ឍន៍ជនបទនិង<br>- ក្រុមអ្នកម៉ៅការ |

| ឧបករណ៍វាស់វែង និងសកម្មភាព | | ពេលវេលា | អង្គភាពទទួលខុសត្រូវ/អាជ្ញាធរ |
|---|---|---|---|
| ២.៣ | **វិធានការសុវត្ថិភាពការងារនិងសុខភាព (OHS)**<br>ត្រូវអនុវត្តវិធានការសុវត្ថិភាពការងារ និងសុខភាព (OHS) ជាផ្នែកមួយនៃ EMSF និង ESMPs និមួយៗនៅ ក្នុងសមាសភាគ១ និងសមាសភាគ ២។<br>ត្រូវធ្វើឱ្យប្រាកដថាក្រុមអ្នកម៉ៅការ និងក្រុមទីប្រឹក្សា ត្រួតពិនិត្យ បានចាត់តាំងបុគ្គលិក ទទួលខុសត្រូវចំពោះការអនុវត្តវិធានការ OHS។<br>រៀបចំការបណ្តុះបណ្តាលកម្មករគម្រោងដែលត្រូវបានចាត់តាំង ដើម្បីបង្កើនការយល់ដឹងអំពីហានិភ័យ OHS និងតម្រូវការរួមបញ្ចូលនៅ LMP (រួមទាំងក្រមសីលធម៌របស់កម្មករ)។ | - អនុវត្តពេញមួយវដ្តនៃការអនុវត្តគម្រោង | - ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងអភិវឌ្ឍន៍ជនបទនិង<br>- ក្រុមអ្នកម៉ៅការ |
| **ESS ៣: ប្រសិទ្ធភាពនៃការគ្រប់គ្រងធនធាន និងការការពារការបំពុលបរិស្ថាន** | | | |
| ៣.១ | **ផែនការគ្រប់គ្រងកាកសំណល់៖**<br>ត្រូវអនុវត្តផែនការគ្រប់គ្រងកាកសំណល់ ដែលជាផ្នែកមួយនៃ ESMPs ជាក់លាក់ក្រោមសកម្មភាព ១.២ និង ១.៣ ខាងលើ ដើម្បីគ្រប់គ្រងសំណល់ដែលមានគ្រោះថ្នាក់ និងមិនមានគ្រោះថ្នាក់ ស្របតាម ESS3។ | - អនុវត្តពេញមួយវដ្តនៃការអនុវត្តគម្រោង | - ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងអភិវឌ្ឍន៍ជនបទ និង<br>- ក្រុមអ្នកម៉ៅការ |

| ឧបករណ៍វាស់វែង និងសកម្មភាព | | ពេលវេលា | អង្គភាពទទួលខុសត្រូវ/អាជ្ញាធរ |
|---|---|---|---|
| ៣.២ | **ប្រសិទ្ធភាពនៃការគ្រប់គ្រងធនធាន និងការការពារ ការបំពុលបរិស្ថាន**<br>ត្រូវអនុវត្តវិធានការឲ្យមានប្រសិទ្ធភាពសម្រាប់ធនធាន និងការទប់ស្កាត់ការបំពុលបរិស្ថាន គឺជាផ្នែកមួយនៃ ESMPs នីមួយៗ។ | - អនុវត្តពេញមួយវដ្តនៃការអនុវត្តគម្រោង | - ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងអភិវឌ្ឍន៍ជនបទ និង<br>- ក្រុមអ្នកម៉ៅការ<br>- |
| ESS ៤: សុខភាព និងសុវត្ថិភាពសហគមន៍ | | | |
| ៤.១ | **សុវត្ថិភាពចរាចរណ៍ និងផ្លូវថ្នល់÷**<br>ត្រូវអនុវត្តវិធានការ និងសកម្មភាពដើម្បីវាយតម្លៃ និងគ្រប់គ្រងហានិភ័យចរាចរណ៍ និងសុវត្ថិភាពផ្លូវថ្នល់តាមតម្រូវការក្នុង ESMPs (សមាសភាគ ១) និងអនុគម្រោងក្នុង ESMPs ដែលមានចែងនៅក្នុង ESMF (សមាសភាគ ២) មានលើកឡើងក្នុងសកម្មភាព ១.២ និង ១.៣ ខាងលើ។ | - អនុវត្តពេញមួយវដ្តនៃការអនុវត្តគម្រោង | - ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងអភិវឌ្ឍន៍ជនបទ និង<br>- ក្រុមអ្នកម៉ៅការ |

| | | | |
|---|---|---|---|
| ៤.២ | **សុខភាព និងសុវត្ថិភាពសហគមន៍**<br>ត្រូវអនុវត្តវិធានការ និងសកម្មភាពដើម្បីវាយតម្លៃ និងគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់ជាក់លាក់ចំពោះសហគមន៍ដែលកើតចេញពីសកម្មភាពរបស់គម្រោង រួមមាន អន្តរសកម្មភាព អាកប្បកិរិយារបស់កម្មករ របស់អ្នកម៉ៅការ ហានិភ័យនៃលំហូរការងារ ការឆ្លើយតបទៅនឹងស្ថានភាពសង្គ្រោះបន្ទាន់ដូចដែលបានរៀបរាប់នៅក្នុង ESMPs (សមាសភាគ ១) និង អនុគម្រោងនៅក្នុង ESMPs ផ្អែកលើ ESMF (សមាសភាគ ២) ក្នុងលក្ខខ័ណ្ឌដែលធនាគារអាចទទួលយកបាន។ | - អនុវត្តពេញមួយវដ្តនៃការអនុវត្តគម្រោង | - ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងអភិវឌ្ឍន៍ជនបទ និង<br>- ក្រុមអ្នកម៉ៅការ |

| | | | |
|---|---|---|---|
| ៤.៣ | **អំពើហឹង្សា លើយេនឌ័រ ការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពាន និងអំពើហឹង្សាលើកុមារ**<br>**(GBV, SEA and VAC RISKS)**<br>ត្រូវអនុវត្តផែនការសកម្មភាពអំពើហិង្សា លើយេនឌ័រ (ផែនការសកម្មភាព GBV) ដូចតម្រូវនៅក្នុង ESMPs (សមាសភាគ ១) និងអនុគម្រោង នៅក្នុង ESMPs ដោយផ្អែកលើ ESMF (សមាសភាគ ២) ដើម្បីគ្រប់គ្រងហានិភ័យនៃអំពើហិង្សាលើយេនឌ័រ (GBV) ការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពាន (SEA) និងអំពើហិង្សាលើកុមារ (VAC) ។ | - អនុវត្តពេញមួយរដ្ឋនៃការអនុវត្តគម្រោង | - ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងអភិវឌ្ឍន៍ជនបទ និង<br>- ក្រុមអ្នកម៉ៅការ |

| ESS ៥: ការធ្វើលទ្ធកម្មដី ការរឹតបន្តឹងលើការប្រើប្រាស់ដី និងការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត | | | |
|---|---|---|---|
| ៥.១ | **ក្របខ័ណ្ឌគោលនយោបាយនៃការដោះស្រាយផលប៉ះពាល់**<br>រក្សា និងអនុវត្តតាមក្របខ័ណ្ឌគោលនយោបាយនៃការដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងស្របតាម ESS5 | - អនុវត្តពេញមួយវដ្តនៃការអនុវត្តគម្រោង | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន |
| ៥.២ | **ផែនការដោះស្រាយផលប៉ះពាល់**<br>អនុវត្តផែនការដោះស្រាយផលប៉ះពាល់ (RPs) សម្រាប់សមាសភាគទី ១ ក្នុងករណី ការតាំងទីលំនៅថ្មីដោយអចេតនា ត្រូវ គិតគូរពីអនុគម្រោង RPs ដែលមានចែងនៅក្នុងក្របខ័ណ្ឌគោលនយោបាយការតាំងទីលំនៅថ្មី (RPF) សម្រាប់សមាសភាគ ២ ស្របតាម ESS ៥ ក្នុងលក្ខណៈដែលអាចទទួលយកបានរបស់ធនាគារ។<br>រក្សា និងអនុវត្តតាមក្របខណ្ឌគោលនយោបាយនៃការតាំងលំនៅថ្មីសម្រាប់គម្រោងស្របតាម ESS ។ | - សម្រាប់សមាសភាគ ១ RPs - អនុវត្តមុនពេលចាប់ផ្តើមសកម្មភាពគម្រោងដែលពាក់ព័ន្ធនឹងការធ្វើលទ្ធកម្មដី និងការដោះស្រាយផលប៉ះពាល់ ។<br>- សម្រាប់សមាសភាគ ២ RPs ដែលមាន នៅក្នុង RPF - អនុវត្តមុនពេលទទួលបានដី និងការដោះស្រាយផលប៉ះពាល់ និងពេញមួយវដ្តនៃការអនុវត្តគម្រោង។ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន |

| | | | |
|---|---|---|---|
| ៥.៣ | **យន្តការដោះស្រាយបណ្តឹងសារទុក្ខ**<br>ជាផ្នែកមួយនៃ RPs និង RPF ដែលបានបញ្ជាក់ក្នុងចំនុច ៥.១. និង៥.២. រក្សាយន្តការដោះស្រាយបណ្តឹងសារទុក្ខ (GRM) សម្រាប់ប្រជាពលរដ្ឋដែលអាចរងផលប៉ះពាល់ដោយសារការធ្វើលទ្ធកម្មដីធ្លី។ | - សម្រាប់សមាសភាគ ១ RPs - បង្កើត និងអនុវត្តមុនពេលចាប់ផ្តើមសកម្មភាពគម្រោងដែលពាក់ព័ន្ធនឹងការធ្វើលទ្ធកម្មដី និងការដោះស្រាយផលប៉ះពាល់ និងពេញមួយវដ្តនៃការអនុវត្តគម្រោង។<br>- សម្រាប់សមាសភាគ 2 RPs ផ្អែកលើ RPF - អនុវត្តមុនពេលទទួលបានដី និងការដោះស្រាយផលប៉ះពាល់ និងពេញមួយវដ្តនៃការអនុវត្តគម្រោង។ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន |

| | | | |
|---|---|---|---|
| **ESS ៦: ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិ ប្រកបដោយនិរន្តរភាព** | | | |
| **៦.១** | **ហានិភ័យ និងផលប៉ះពាល់ជីវៈចម្រុះ**<br>អនុវត្តវិធានការដើម្បីដោះស្រាយហានិភ័យ និងផលប៉ះពាល់នៃជីវចម្រុះ ដែលជាផ្នែកមួយនៃ ESMF និង ESMPs នីមួយៗ នៅក្នុងសមាសភាគទី ១ និងទី ២។ | - អនុវត្តពេញមួយវដ្តនៃការអនុវត្តគម្រោង | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន |
| **ESS ៧: ជនជាតិដើមភាគតិច/អនុតំបន់សាហារា ប្រទេសអាហ្វ្រិក សហគមន៍មូលដ្ឋានប្រពៃណី ប្រវត្តិសាស្ត្រ** | | | |
| **៧.១** | **ជនជាតិដើមភាគតិច**<br>សម្រាប់សមាសភាគទី ២ អនុវត្តក្របខ័ណ្ឌផែនការជនជាតិដើមភាគតិច (IPPF) រួមទាំងការស្នើសុំការយល់ព្រមជាមុនដោយឥតគិតថ្លៃ (FPIC) ដោយអនុលោមតាម ESS7 និង IPPF ដែលត្រូវបានរៀបចំសម្រាប់គម្រោង និង ESS7 ក្នុងលក្ខខ័ណ្ឌដែលអាចទទួលយកបានសម្រាប់ធនាគារ។ | - សម្រាប់សមាសភាគទី ២ - អនុវត្ត IPPF ពេញមួយវដ្តនៃការអនុវត្តគម្រោង ប្រសិនបើ IPs ត្រូវបានរកឃើញ សូមរៀបចំ IPP កំឡុងពេលអនុវត្តគម្រោង | - ក្រសួងអភិវឌ្ឍន៍ជនបទ |

| | | | |
|---|---|---|---|
| ៧.២ | **យន្តការដោះស្រាយបណ្តឹងសារទុក្ខ**<br>រៀបចំ ពិគ្រោះ អនុម័ត និងអនុវត្តការរៀបចំសម្រាប់យន្តការដោះស្រាយបណ្តឹងសារទុក្ខសម្រាប់ជនជាតិដើមភាគតិច ដូចដែលមាន នៅក្នុង IPPF និងពណ៌នាបន្ថែមអំពីការរៀបចំបែបនេះនៅក្នុង IPPs នីមួយៗ (ប្រសិនបើយន្តការដោះស្រាយបណ្តឹងសារទុក្ខមានលក្ខណៈខុសប្លែកពីអ្វីដែលបង្កើតឡើងក្រោម ESS10)។ | - សម្រាប់សមាសភាគទី ២ ផ្អែកលើ IPPF រៀបចំមុនពេលបញ្ចប់ការវាយតម្លៃគម្រោង និងអនុវត្តពេញមួយវដ្តនៃការអនុវត្តគម្រោង។ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន |
| **ESS 8: បេតិកភណ្ឌវប្បធម៌** | | | |
| ៨.១ | **នីតិវិធីនៃការរកឃើញវត្ថុបុរាណ**<br>អនុវត្តតាមនីតិវិធីពេលរកឃើញវត្ថុបុរាណ ដែលជាផ្នែកមួយនៃ ESMF និង ESMPs នីមួយៗ។ | - អនុវត្តពេញមួយវដ្តនៃការអនុវត្តគម្រោង | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន |
| **ESS ១០: ការចូលរួមរបស់ភាគីពាក់ព័ន្ធ និងការផ្សព្វផ្សាយព័ត៌មាន** | | | |

| | | | |
|---|---|---|---|
| ១០.១ | **ការរៀបចំផែនការអនុវត្តស្ដីពីការចូលរួមរបស់ភាគីពាក់ព័ន្ធ**<br>អនុវត្តផែនការស្ដីពីការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) សម្រាប់គម្រោងស្របតាម ESS10 ដែលរួមមានវិធានការដើម្បីភាគីពាក់ព័ន្ធទទួលបានព័ត៌មានទាន់ពេលវេលា អាចយល់បាន និងពិគ្រោះយោបល់ជាមួយពួកគាត់ ដោយមិនមានការបង្ខិតបង្ខំ ការរើសអើង និងការគំរាមកំហែង។ | - អនុវត្តពេញមួយវដ្តនៃការអនុវត្តគម្រោង | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន |

| | | | |
|---|---|---|---|
| ១០.២ | **យន្តការដោះស្រាយបណ្តឹងសារទុក្ខរបស់គម្រោង**<br>MRD និង MPWT ត្រូវរក្សា និងដំណើរការយន្តការបណ្តឹងសារទុក្ខ ដែលអាចអនុវត្តទៅបាន ដើម្បីទទួល សម្របសម្រួលដោះស្រាយក្តីបារម្ភផ្សេងៗពាក់ព័ន្ធនឹងគម្រោងឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធិភាពខ្ពស់ ប្រកបដោយតម្លាភាព សមស្របតាមវប្បធម៌ ហើយអាចឱ្យភាគីដែលរងផលប៉ះពាល់អាចធ្វើទៅរួច មិនចំណាយថវិកា និងរក្សាការសម្ងាត់ ស្របតាម ESS10 ក៏ជាអ្វីដែលបានពិណនាក្នុង SEP។<br>យន្តការបណ្តឹងសារទុក្ខ គួរតែរៀបចំឱ្យមានអ្នកទទួល កត់ត្រា និងសម្របសម្រួលរកដំណោះស្រាយ ដោយរួមមានអ្នកផ្តល់ សេវាផ្នែកហឹង្សាលើយេនឌ័រ អ្នកទាំងនោះត្រូវបានការពារសុវត្ថិភាព រក្សាការសម្ងាត់ និងការពារអាយុជីវិត។ | | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន |
| **ការគាំទ្រសមត្ថភាព (ការបណ្តុះបណ្តាល)** | | | |

| | | | |
|---|---|---|---|
| CS1 | ១. ធនាគារ អ្នកម៉ៅការ អ្នកម៉ៅការបន្ត និងអ្នកត្រួតពិនិត្យការដ្ឋាន/វិស្វករ អ្នកម៉ៅការបន្ត និងក្រុមហ៊ុនទីប្រឹក្សា គាំទ្រការអនុវត្ត។ ការបណ្តុះបណ្តាលដែលត្រូវបានផ្តល់ដោយ SEO នៃ MRD និង MPWT ដោយមានការគាំទ្រពីធនាគារ លើតម្រូវការរបស់ ESF ESSs ស្តីពីហានិភ័យ E&S នៅកម្រិតអ្នកម៉ៅការ អ្នកម៉ៅការបន្ត និងទីប្រឹក្សាបច្ចេកទេស រួមមាន ESHS, OHS, RP, IPPF, EGDP , GBV, VAC, SEP និង GRM ។<br>២. សហគមន៍÷ សុវត្ថិភាពផ្លូវថ្នល់ GBV, VAC, SEP និង GRM និង ESMPs និង ESMF ដែលជាមូលដ្ឋាននៃគម្រោង។<br>៣. ដោយមានការត្រួតពិនិត្យពីទីប្រឹក្សាបច្ចេកទេស និងក្រុមការងារអនុវត្តគម្រោងរបស់ MRD និង MPWT ត្រូវប្រាកដថាកម្មករគម្រោង ក្រោមការគ្រប់គ្រងរបស់អ្នកម៉ៅការ និងអ្នកម៉ៅការបន្តត្រូវចុះហត្ថលេខាលើឯកសារក្រមសីលធម៌របស់អ្នកម៉ៅការ និងកម្មករ ហើយពួកគាត់ត្រូវទទួលបានការបណ្តុះបណ្តាលក្រមសីលធម៌ផ្សេងៗរួមមាន ESHS, OHS, GBV, VAC, SEP, និងGRM។ | យ៉ាងហោចណាស់មួយខែមុនចាប់ផ្តើមការងារសាងសង់ ។<br><br>យ៉ាងហោចណាស់មួយខែមុនចាប់ផ្តើមការងារសាងសង់ ។<br><br>យ៉ាងហោចណាស់មួយខែមុនចាប់ផ្តើមការងារសាងសង់ និងពេញមួយវដ្តនៃការអនុវត្តការងារផ្លូវ ។ | - SEO របស់ MRD និង MPWT ដោយមានការគាំទ្រពីធនាគារ។<br><br>- SEO របស់ MRD និង MPWT<br><br>- អ្នកម៉ៅការ ទីប្រឹក្សាបច្ចេកទេស និងក្រុមការងារអនុវត្តន៍គម្រោងរបស់ MPWT និង MRD |